សាលាសាធារណៈភទឡៃន
ក្រសួងសេវាម្ហូបអាហារ
**Accounting Bulletin 100 - F**
វិធីបង់ប្រាក់អាហារសិស្សសាលា

ឧសភា ២០១៧

គោលបំណងសាលារៀនគឺផ្តល់សិស្ស នូវអាហារមានជីវជាតិល្អរៀងរាល់ថ្ងៃ។ ទោះជាយ៉ាងនេះក្តី ចំពោះសិស្ស ដែលខកខានបង់ប្រាក់ បានធ្វើឱ្យមានការលំបាកយ៉ាងខ្លាំង ចំពោះក្រសួងខាងម្ហូបអាហារសិស្ស។ ក្នុងខណៈដែលកម្មវិធីម្ហូបអាហារក្មេង USDA មិនតម្រូវថា សិស្សណាមួយ ដែលបង់ថ្លៃម្ហូបតាមតម្លៃធម្មតា ត្រូវតែបានទទួលម្ហូបអាហារ ដោយពុំបានបង់ប្រាក់ សាលាត្រូវតែធ្វើ សម្រាក់សិស្សទាំងឡាយណា ដែលភ្លេចបង់ឬបាត់ប្រាក់អាហារថ្ងៃត្រង់។

នៅក្នុងកំណត់ហេតុរបស់ USDA Memo Code SP46-2016 សហរដ្ឋអាមេរិកតម្រូវឱ្យអាជ្ញាធរខាងម្ហូបអាហារ បង្កើតការតាមដាននិងទារសំណង ចំពោះសិស្សណា ដែលបង់ប្រាក់មិនគ្រប់ចំនួន។

ក្រសួងម្ហូបអាហារនឹងផ្តើមអនុវត្តតាមវិធានការខាងក្រោមនេះ យ៉ាងទៀងទាត់ ដោយយល់ថា សិស្សទាំងឡាយនោះ ពេលខ្លះ ភ្លេចប្រាក់ម្ហូបសាលា។ យើងធ្វើការ ក្នុងន័យថា បង្រៀនក្មេងឱ្យមានស្មារតីទទួលខុសត្រូវ និងឈានទៅរកសេវា ដែលផ្អែកលើថវិការ ជាមូលដ្ឋាន។ នេះគឺជា គោលបំណងមួយ របស់ក្រសួងយើង ដែលថា សិស្សគ្រប់រូបត្រូវមានសល់ប្រាក់ក្នុងលេខអាក់ខោន របស់ខ្លួនជានិច្ច។

តាមសេចក្តីគួរសម របស់យើង បើប្រាក់នៅសល់តែ៥ដុល្លារក្នុងលេខអាក់ខោនសិស្ស យើងនឹងនឹងផ្ញើសំបុត្ររំលឹកទៅគ្រួសារសិស្ស។

បើទោះជាខើចប្រាក់ក្នុងអាក់ខោននេះក្តី សិស្សទាំងឡាយ នឹងត្រូវបានទទួលអាហារតាមធម្មតា ហើយត្រូវចុះជាប្រាក់ជំពាក់ក្នុងលេខអាកខោន របស់ខ្លួន។

បើមិនមានសល់ប្រាក់ក្នុងអាក់ខោនសោះ សម្លេងទូរស័ព្ទនិងអ៊ីម៉ែលនឹងធ្វើឡើងជាបន្ទាន់។ សម្លេងទូរស័ព្ទនឹងហៅចេញថ្ងៃច័ន្ទ ពុធ និងថ្ងៃសុក្រ។ រីឯសិស្សបឋមសិក្សា សំបុត្រនឹងផ្ញើទៅផ្ទះម្តងក្នុងមួយអាទិត្យ តាមរយៈកាបូបស្ពាយ របស់សិស្ស។

បើមិនមានចម្លើយពីគ្រួសារ បន្ទាប់ពីសិស្សបឋមសិក្សា ជំពាក់ប្រាក់៥លើក និង៣លើក សិស្សមធ្យមសិក្សា ថ្នាក់ដឹកនាំសាលានឹងផ្តើមធ្វើការទារសំណង ឬថា **collection procedures**។

លំដាប់ នៃការទាមទារសំណងនេះ ផ្តើមដោយនាយកខាងម្ហូបអាហារ បន្ទាប់មក ដោយនាយកគម្រោងថវិការនិងការចំណាយ និងចុងក្រោយ ដោយលោកអគ្គនាយកសាលា។

ការបង្វិលប្រាក់ទៅសិស្សវិញ

- សិស្ស ដែលឈប់រៀនបន្តទៅទៀត អាចសរសេរសំបុត្រសុំប្រាក់វិញ ពីលេខអាក់ខោន របស់ខ្លួន។ ការសរសេរអ៊ីម៉ែលក៏បានដែរ។សំណូមពរ

ត្រូវឡើងក្នុងរយៈពេល៦០ថ្ងៃ ក្រោយសិស្សផ្លូវសាលា និងក្នុងឆ្នាំជាមួយគ្នា។

- វានឹងមិនមានការបង្វិលប្រាក់វិញទេ ចំពោះសិស្សទាំងឡាយ ដែលបានបញ្ចប់ថ្នាក់នៅបំណាច់ឆ្នាំនិមួយៗ។ ប្រាក់នៅសល់នោះ អាចបញ្ជូលទៅក្នុងលេខអាក់ខោនផ្សេង របស់កូនអ្នក តាមលិខិតស្នាម ហើយត្រូវធ្វើមុនបំណាច់ឆ្នាំ។

ប្រាក់សិស្សជំពាក់មុនបំណាច់ឆ្នាំ

- លេខអាក់ខោនអាចឆែកមើលបាន គ្រប់ពេល ដោយចូលទៅក្នុង Paypams.com ចុច

  Infinite Campus ឬសាកសួរបុគ្គលិកម្ហូបអាហារ នៃសាលារបស់អ្នក។
- គ្រប់ប្រាក់ជំពាក់ តម្រូវតែសងមុនបំណាច់ឆ្នាំនិមួយៗ។ នៅថ្ងៃទី១ មិថុនា គ្រួសារនឹងត្រូវបានជូនដំណឹង បើសិនជាគេជំពាក់ប្រាក់។ ការជំពាក់

  ត្រូវសងវិញឱ្យបានគ្រប់ចំនួន។
- ក្រសួងចាត់ទុកថា បំណុលអាក្រក់ គឺបំណុល ដែលទារមិនបាន ឬចំណាយក្រៅបញ្ជី។

  សេវាម្ហូបអាហារ មិនត្រូវបានអនុញ្ញាតទុកបំណុលទៅឆ្នាំបន្ទាប់ទេ ដូច្នេះ បំណុល ពេលសិស្សចប់សលា ត្រូវទៅសុំសំណងពី general

  fund ហើយដកលេខអាក់ខោននោះចេញពីសេវាម្ហូបអាហារ។

ប្រាក់នៅសល់ នឹងរក្សាទុកក្នុងអាក់ខោនសិស្ស នៅឆ្នាំបន្ទាប់។

ប្រាក់ណា ដែលមិនមានអ្នកទាមទារ នឹងត្រូវក្លាយជាទ្រព្យ របស់សេវាម្ហូបអាហារសាលាសាធារណៈភទឡ្វែន។